- លោក **វ៉ាន ពេជ្រ** ប្រជាជនភូមិត្រួនៈ ចំពោះប្រជាជនដែលរស់នៅតំបន់នេះភាគច្រើនគឺប្រកបមុខរបរជីករ៉ែមាស ដើម្បីចិញ្ចឹមជីវិត ប្រសិនជាក្រុមហ៊ុនបិទមិនអោយប្រជាជនរករ៉ែមាសនោះទេ ប្រជាជនតំបន់នេះមិនដឹងជាពឹងផ្អែកទៅលើអ្វីនោះទេ។ ប្រជាជនដែលរស់នៅក្នុងភូមិនេះពុំមានទឹក ស្អាតសំរាប់ប្រើប្រាស់នោះទេគឺទិញទឹកពីខាងក្រៅក្នុងមួយ៣០លីត្រ តំលៃ២០០០រៀល ដូច្នេះសូមអោយក្រុមហ៊ុនជួយសាងសង់អណ្តូងទឹកស្អាត ឬស្រះទឹក អោយប្រជាជនក្នុងភូមិបានប្រើប្រាស់ផង ដើម្បីកាត់បន្ថយការទិញទឹកពីខាងក្រៅ។ លើសពីនេះទៅទៀត សូមអោយក្រុមហ៊ុនជួយសាងសង់សាលារៀន ប៉ុស្តិ៍សុខភាព អណ្តូងទឹកស្អាត និងបង្គន់អនាម័យ ដើម្បីកាត់បន្ថយនូវផលពិបាកកន្លងមក។